វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២០ ខែកក្កដា ២០១៨**

---

ចំនុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ការនាំចេញកៅស៊ូនៅកម្ពុជាបានកើនឡើងនៅឆមាសដំបូង ក្នុងឆ្នាំ២០១៨
- គោលនយោបាយការងារនៅប្រទេសកូរ៉េខាងត្បូង ប៉ះពាល់ដល់អ្នកដែលគ្មានការងារធ្វើ និងបុគ្គលិកដែលទទួលបានប្រាក់ចំនួលទាប
- ទេសាភិបាលធនាគារសហព័ន្ធអាមេរិក លោកផូវែល (Powell) លើកឡើងថា សង្គ្រាមពាណិជ្ជកម្មអាចប៉ះពាល់ដល់សេដ្ឋកិច្ចសហរដ្ឋអាមេរិក

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធ របស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំនងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការនាំចេញកៅស៊ូនៅកម្ពុជាមានការកើនឡើង នៅក្នុងឆមាសដំបូង ក្នុងឆ្នាំនេះ

ការនាំចេញកៅស៊ូរបស់កម្ពុជា បានកើនឡើង២១ភាគរយនៅក្នុងឆមាសដំបូងនាឆ្នាំ២០១៨ បើធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។ ជាសរុប កម្ពុជាបាននាំចេញកៅស៊ូចំនួន ៨៤,៤១៩ តោន នៅក្នុង៦ខែដំបូង ឆ្នាំ២០១៨។ ការដាំដុះដំណាំកៅស៊ូក៏បានកើនឡើងរហូតដល់៤៣៦,២៩៩ ហិកតាផងដែរ។ តួលេខទាំងនេះត្រូវបានប្រកាសដោយ អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ របស់ក្រសួងកសិកម្ម កាលពីថ្ងៃអាទិត្យកន្លងទៅនេះ។

យ៉ាងណាមិញ ព័ត៌មានដែលមិនល្អនោះគឺ តម្លៃកៅស៊ូបានធ្លាក់ចុះ ២០ភាគរយបើធៀបនឹងឆ្នាំមុន ដែលថ្លៃកៅស៊ូនាំចេញមានតម្លៃជាមធ្យម ១,៤៣៤ដុល្លារអាមេរិក ក្នុង១តោន។ ទោះជាយ៉ាងណាក៏ដោយ ដំណាំកៅស៊ូដើរតួនាទីយ៉ាងសំខាន់ នៅក្នុងទស្សនៈវិស័យកំណើនសេដ្ឋកិច្ចកម្ពុជានាពេលអនាគត។

### តារាងប្រចាំសប្តាហ៍៖ ការចូលរួមរបស់វិស័យធ្វើដំណើរ និងទេសចរណ៍ ទៅក្នុងផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) នៅក្នុងប្រទេសកម្ពុជា

តារាងប្រចាំសប្តាហ៍នេះ បង្ហាញពីការចូលរួមរបស់វិស័យធ្វើដំណើរ និងទេសចរណ៍នៅក្នុងផ.ស.ស. របស់ប្រទេសកម្ពុជា។ ទាំងសកម្មភាពសេដ្ឋកិច្ចផ្ទាល់នៅក្នុងវិស័យទេសចរណ៍ និងសកម្មភាពសេដ្ឋកិច្ចសរុបដែលទ្រទ្រង់ដោយវិស័យទេសចរណ៍ (រួមបញ្ចូលទាំងការងារដែលពឹងផ្អែកដោយប្រយោល ទៅលើវិស័យនេះ) ដែលចូលរួមនៅក្នុងផ.ស.ស. បានធ្លាក់ចុះ តាំងពីឆ្នាំ២០១៧ និង

ត្រូវបានប៉ាន់ស្មានថា នឹងបន្តធ្លាក់ចុះទៀតនៅរយៈពេល១០ឆ្នាំបន្ទាប់ គឺរហូតដល់ឆ្នាំ២០២៨ (ទោះបីជាតម្លៃជាក់ស្តែង (Normal Value) ដែលបានមកពីវិស័យនេះ នឹងបន្តកើនឡើងគួរអោយកត់សម្គាល់ក៏ដោយ)។

ការចូលរួមសរុបរបស់វិស័យទេសចរណ៍នៅក្នុងឆ្នាំ២០១៧ មានចំនួន ២៩,១៣១.២ ពាន់លានរៀល (ប្រមាណ៧.២ ពាន់លានដុល្លារអាមេរិក) ឬស្មើនឹង៣២.៤ភាគរយនៃផ.ស.ស. សរុបនៅក្នុងឆ្នាំ២០១៧។ គេរំពឹងថា តួលេខនេះនឹងធ្លាក់ចុះដល់២៨.៣ភាគរយត្រឹមឆ្នាំ២០២៨។

តារាងប្រចាំសប្តាហ៍៖ ការចូលរួមដោយផ្ទាល់ (ឆ្វេង) និងការចូលរួមសរុប (ស្តាំ) របស់វិស័យធ្វើដំណើរ និងទេសចរណ៍ទៅក្នុងផ.ស.ស. របស់ប្រទេសកម្ពុជា (ជាភាគរយ)




ប្រភព៖ ក្រុមប្រឹក្សាទេសចរណ៍ពិភពលោក (World Travel and Tourism Council)

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### គោលនយោបាយការងាររបស់ប្រទេសកូរ៉េខាងត្បូង ប៉ះពាល់ដល់អ្នកដែលគ្មានការងារធ្វើ និងបុគ្គលិកដែលទទួលបានប្រាក់ចំណូលទាប

ប្រាក់ចំណូលគ្រួសារដែលស្ថិតក្នុងក្រុមចំនាត់ថ្នាក់ចំណូលទាបជាងគេ២០ភាគរយ របស់ប្រទេសកូរ៉េខាងត្បូង បានធ្លាក់ចុះ ៨ភាគរយ នៅក្នុងត្រីមាសទីមួយក្នុងឆ្នាំ២០១៨ បើធៀបនឹងមួយឆ្នាំមុន ដែលនេះគឺជាការធ្លាក់ចុះដ៏ធំមួយ គិតចាប់តាំងពីការស្រង់ស្ថិតិត្រូវបានចាប់ផ្តើមធ្វើឡើងក្នុងឆ្នាំ២០០៣។ ស្របពេលជាមួយគ្នានេះ ការបង្កើតការងារ ដែលមានចំនួនជាមធ្យម ១៤២,០០០ ការងារនៅក្នុងឆ្នាំនេះ គឺជាកំណើនការងារដែលយឺតបំផុត ចាប់តាំងពីវិបត្តិហិរញ្ញវត្ថុពិភពលោកឆ្នាំ២០០៨-២០០៩មក នេះបើយោងតាម អង្គភាពស្ថិតិរបស់ប្រទេសកូរ៉េ។

ការថយចុះនៅក្នុងទីផ្សារការងារ មួយភាគធំគឺបណ្តាលមកពីគោលនយោបាយរបស់លោកប្រធានាធិបតី មូន ជេអ៊ីន (Moon Jae-in) ក្នុងការតម្លើងប្រាក់ឈ្នួលអប្បបរមា៖ ក្នុងខែមករាឆ្នាំនេះ ប្រាក់ឈ្នួលអប្បបរមាប្រចាំម៉ោងត្រូវបានកើនឡើង ១៦ភាគរយ។ ជាអកុសល ឥទ្ធិពលនៃគោលនយោបាយអាចផ្ទុយពីការរំពឹងទុក ពោលគឺផ្តល់ផលប៉ះពាល់អវិជ្ជមាន ដល់គ្រួសារដែលទទួលបានប្រាក់ចំណូលទាប ព្រោះបុគ្គលិកខ្លះត្រូវបានគេកាត់បន្ថយម៉ោងការងារ និងតួនាទី។

## សេដ្ឋកិច្ចអាមេរិក និងធនាគារសហព័ន្ធ

### ទេសាភិបាលធនាគារសហព័ន្ធនៅសហរដ្ឋអាមេរិក លោកផូវែល (Powell) លើកឡើងថា សង្គ្រាមពាណិជ្ជកម្មអាចប៉ះពាល់ដល់សេដ្ឋកិច្ចសហរដ្ឋអាមេរិក

ទេសាភិបាលធនាគារសហព័ន្ធនៅអាមេរិក លោកជេរ៉ូម ផូវែល (Jerome Powell) បានប្រាប់គណៈកម្មាធិការទទួលបន្ទុកធនាគាររបស់ព្រឹទ្ធសភាអាមេរិក នៅក្នុងសវនការស្តីពីគោលនយោបាយរូបិយវត្ថុរបស់ធនាគារសហព័ន្ធ និងសេដ្ឋកិច្ច កាលពីថ្ងៃអង្គារកន្លងមកថា សង្គ្រាមពាណិជ្ជកម្មជាមួយប្រទេសចិន សហភាពអឺរ៉ុប និងដៃគូពាណិជ្ជកម្មដ៏ទៃទៀត អាចនឹងប៉ះពាល់ដល់សេដ្ឋកិច្ចអាមេរិកនាពេលអនាគត។ បច្ចុប្បន្ននេះ ធនាគារសហព័ន្ធរំពឹងថា សេដ្ឋកិច្ចអាមេរិកនឹងនៅតែមានភាពរឹងមាំ ប៉ុន្តែគោលនយោបាយពាណិជ្ជកម្មដែលពិបាករំពឹងទុករបស់លោកប្រធានាធិបតី ត្រាំ បានធ្វើអោយការព្យាករណ៍របស់ធនាគារសហព័ន្ធអាមេរិក ប្រឈមនឹងការផ្ទុយពីការរំពឹងទុក។

ក្តីបារម្ភនេះត្រូវបានលើកឡើងផងដែរ ដោយសមាជិកព្រឹទ្ធសភាដែលតំណាងអោយវិស័យកសិកម្ម និងឧស្សាហកម្មរបស់ប្រទេសដែលមណ្ឌលបោះឆ្នោតរបស់ខ្លួន កំពុងបារម្ភនឹងបញ្ហានេះផងដែរ (ប្រភព៖ វិទ្យុសាធារណៈជាតិ National Public Radio)។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ព័ត៌មាននៅសប្តាហ៍បន្ទាប់រួមមាន កំណើនផ.ផ.ស. របស់សហរដ្ឋអាមេរិក ប្រទេសកូរ៉េខាងត្បូង និងប្រទេសប្រ៊ុយណេ, អត្រាអ្នកគ្មានការងាររបស់ប្រទេសសិង្ហបុរី និងទិន្នន័យតុល្យភាពថវិការបស់ប្រទេសហ្វីលីពីន។

ប្រតិទិនខាងក្រោមនេះ បង្ហាញពីទិន្នន័យព័ត៌មាន និងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា សហរដ្ឋអាមេរិក និងប្រទេសជាដៃគូពាណិជ្ជ-កម្ម ដែលក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើ-ពន្ធ នឹងបន្តតាមដាន និងស្រាវជ្រាវនាសប្តាហ៍បន្ទាប់ ។

<u>ថ្ងៃច័ន្ទ ទី២៣ ខែកក្កដា</u>

- តុល្យភាពថវិការបស់ប្រទេសហ្វីលីពីន នៅខែមិថុនា
- អត្រាអតិផរណារបស់ប្រទេសសិង្ហបុរី នៅខែមិថុនា
- ផលិតកម្មផ្នែកឧស្សាហកម្មរបស់ប្រទេសតៃវ៉ាន់ នៅខែមិថុនា
- ទិន្នន័យលក់រាយរបស់ តៃវ៉ាន់ នៅខែមិថុនា
- អត្រាអ្នកគ្មានការងាររបស់ តៃវ៉ាន់ នៅខែមិថុនា
- ផ.ផ.ស. របស់ប្រទេសប្រ៊ុយណេ សម្រាប់ឆមាសទី១ ឆ្នាំ២០១៨
- អត្រាអតិផរណារបស់ទីក្រុងហុងកុង នៅខែមិថុនា
- ទិន្នន័យការលក់ផ្ទះដែលមានស្រាប់ នៅខែមិថុនា

<u>ថ្ងៃអង្គារ ទី២៤ ខែកក្កដា</u>

- សន្ទស្សន៍សូចនាករសេដ្ឋកិច្ចនាំមុខរបស់ប្រទេសជប៉ុន នៅខែឧសភា
- ទិន្នន័យការវិនិយោគបរទេសដោយផ្ទាល់របស់ប្រទេសឥណ្ឌូនេស៊ី សម្រាប់ឆមាសទី២ ឆ្នាំ២០១៨
- សន្ទស្សន៍កំណើននៃ ការលក់រាយរបស់សហរដ្ឋអាមេរិច (U.S. red book) នៅខែកក្កដា

<u>ថ្ងៃពុធ ទី២៥ ខែកក្កដា</u>

- សូចនាករនៃជំនឿទុកចិត្តរបស់អ្នកប្រើប្រាស់សម្រាប់ប្រទេសកូរ៉េ នៅខែកក្កដា
- សន្ទស្សន៍វដ្តសេដ្ឋកិច្ច(Coincident Index) របស់ប្រទេសម៉ាឡេស៊ី នៅខែឧសភា
- សន្ទស្សន៍ នាំមុខរបស់ប្រទេសម៉ាឡេស៊ី នៅខែឧសភា
- ទិន្នន័យការប្រែប្រួលតម្លៃភាគហ៊ុនប្រេងនៅរបស់វិទ្យាស្ថានប្រេងឥន្ធនៈអាមេរិកាំងរបស់អាមេរិក (API) នៅខែកក្កដា

<u>ថ្ងៃព្រហស្បតិ៍ ទី២៦ ខែកក្កដា</u>

- ផ.ផ.ស. របស់ប្រទេសកូរ៉េខាងត្បូង សម្រាប់ឆមាសទី២ ឆ្នាំ២០១៨ (ការប៉ាន់ស្មានកម្រិតខ្ពស់)
- ផលិតកម្មផ្នែកឧស្សាហកម្មរបស់ប្រទេសសិង្ហបុរី នៅខែមិថុនា
- តុល្យភាពថវិការបស់ទីក្រុងហុងកុង នៅខែមិថុនា
- របាយការណ៍អះអាងភាពគ្មានការងាររបស់សហរដ្ឋអាមេរិច នៅខែកក្កដា

<u>ថ្ងៃសុក្រ ទី២៧ ខែកក្កដា</u>

- សន្ទស្សន៍តម្លៃសម្រាប់អ្នកប្រើប្រាស់(CPI) នៅទីក្រុងតូក្យូសម្រាប់ប្រទេសជប៉ុន នៅខែមិថុនា
- ទិន្នន័យប្រាក់ចំណេញសហគ្រាសរបស់ប្រទេសចិន នៅខែមិថុនា
- សូចនាករនៃជំនឿទុកចិត្តរបស់អ្នកប្រើប្រាស់សម្រាប់ តៃវ៉ាន់ នៅខែកក្កដា
- អត្រាអ្នកគ្មានការងាររបស់ប្រទេសសិង្ហបុរីសម្រាប់ឆមាសទី២ ឆ្នាំ២០១៨
- ទិន្នន័យតម្លៃ នាំចេញ-នាំចូលរបស់ប្រទេសសិង្ហបុរី នៅខែមិថុនា
- សន្ទស្សន៍តម្លៃសម្រាប់អ្នកផលិត (PPI) របស់ប្រទេសសិង្ហបុរី នៅខែមិថុនា
- កំណើនផ.ស.ស. របស់សហរដ្ឋអាមេរិកសម្រាប់ឆមាសទី២ ឆ្នាំ២០១៨ ។

*************************